# សេចក្តីជំនឿ សម្បថ និងសេចក្តីសញ្ញានៃបព្វជិតភាព

ប្រធាន ហិនរី បី អាវរិង
ទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ

*ឆ្ពោះទៅមុខ នៅក្នុងការរក្សាសេចក្តីសញ្ញារបស់អ្នកជាមួយនឹងព្រះ ហើយក៏ទាមទារសេចក្តីសន្យាដែលទ្រង់បានធ្វើនឹងអ្នកជាមួយនឹងសម្បថ*

គោលបំណងរបស់ខ្ញុំនៅយប់នេះ គឺដើម្បីជួយដល់អ្នកឱ្យរីកចំរើននូវទំនុកចិត្តរបស់អ្នកថា អ្នកអាចមានភាពសក្តិសមចំពោះពរជ័យទាំងឡាយនៃសម្បថ និងសេចក្តីសញ្ញានៃបព្វជិតភាព។ វាគឺជាទំហំនៃលទ្ធផលដែលអាចកើតមានឡើងនៃសម្បថ និងសេចក្តីសញ្ញានោះ ដែលអាចតំរូវឱ្យមានការជួយលើកស្ទួយជាទៀងទាត់មួយនៅក្នុងទំនុកចិត្តរបស់អ្នក។

ព្រះអម្ចាស់បានបង្ហាញយ៉ាងច្បាស់អំពីលទ្ធផលទាំងនោះ។ ភាពសក្តិសមនឹងទំនួលខុសត្រូវទាំងឡាយនៃសម្បថ និងសេចក្តីសញ្ញា នាំមកនូវអំណោយទានដ៏ពិសេសបំផុតនៃអំណោយទានទាំងអស់របស់ព្រះគឺៈ ជីវិតដ៏នៅអស់កល្បជានិច្ច។ ការទទួលជីវិតដ៏នៅអស់កល្បជានិច្ចនោះ គឺជាគោលបំណងមួយនៃបព្វជិតភាពមិលគីស្សាដែក។ តាមរយៈការរក្សាសេចក្តីសញ្ញាទាំងឡាយ នៅពេលយើងទទួលបព្វជិតភាព និងការរំលឹកសេចក្តីសញ្ញាទាំងនោះឡើងវិញនៅក្នុងពិធីការនៅក្នុងព្រះវិហារបរិសុទ្ធ យើងត្រូវបានសន្យាដោយសម្បថមួយ ដែលបានធ្វើឡើងដោយអេឡូហិម ព្រះវរបិតាសួគ៌របស់យើង ថាយើងនឹងទទួលបាននូវសិរីល្អរបស់ទ្រង់ពេញលេញ ហើយរស់នៅដូចជាទ្រង់។ យើងនឹងមានពរជ័យនៃការផ្សារភ្ជាប់នៅក្នុងគ្រួសារដ៏អស់កល្បជានិច្ចជាមួយនឹងការសន្យានៃការរីកចំរើនដ៏អស់កល្បជានិច្ច។

ដូចដែលអ្នកបានរំពឹងទុក ការមិនទាមទារនូវពរជ័យទាំងនោះនឹងនាំមកនូវលទ្ធផលដ៏អាក្រក់។ ព្រះអម្ចាស់បានជ្រាបយ៉ាងច្បាស់អំពីរឿងនោះ។ ទាំងនេះគឺជាពាក្យសំដី ដែលជារឿយៗបានអានទៅដល់យុវជនទាំងឡាយដោយអ្នកដឹកនាំរបស់ពួកគេ នៅពេលពួកគេឈានចូលដល់ពេល ដែលពួកគេអាចទទួលបព្វជិតភាពមិលគីស្សាដែក។ អ្នកក៏នឹងចងចាំនូវអារម្មណ៏របស់អ្នក នៅពេលអ្នកបានឮអំពីពាក្យទាំងនោះដំបូង។ ពាក្យទាំងនោះគឺជាបន្ទូលរបស់ព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ ដែលបានប្រទានដល់យើងតាមរយៈព្យាការីយ៉ូសែប ស៊្មីធថាៈ

"ហើយអស់អ្នកណាដែលទទួលបព្វជិតភាពនេះ ឈ្មោះថាទទួលយើងដែរ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ត្បិតអ្នកណាដែលទទួលពួកអ្នកបំរើរបស់យើង ឈ្មោះថាទទួលយើងដែរ ហើយអ្នកណាដែលទទួលយើង ឈ្មោះថាទទួលព្រះវរបិតាយើងដែរ ហើយអ្នកណាដែលទទួលព្រះវរបិតាយើង ឈ្មោះថាទទួលនគររបស់ព្រះវរបិតាយើងដែរ ហេតុដូច្នោះហើយ គ្រប់អ្វីៗទាំងអស់ ដែលព្រះវរបិតាយើងមាន នោះនឹងត្រូវបានប្រទានដល់អ្នកនោះដែរ។ ហើយការណ៍នេះ គឺស្របតាមសម្បថ និងសេចក្តីសញ្ញាដែលជារបស់ផងបព្វជិតភាព។ ប៉ុន្តែអស់អ្នកទាំងនោះដែលទទួលបព្វជិតភាព ឈ្មោះថាទទួលសម្បថ និងសេចក្តីសញ្ញានេះ ពីព្រះវរបិតាយើង ដែលទ្រង់ពុំអាចបណ្តាច់ ឬអាចរើបានឡើយ។ ប៉ុន្តែអស់អ្នកណាដែលបណ្តាច់សេចក្តីសញ្ញានេះ បន្ទាប់ពីអ្នកនោះបានទទួលរួចស្រេច ហើយបែរចេញប្រឆើយនោះនឹងមិនត្រូវបានអត់ទោសឱ្យឡើយ ទោះជានៅលោកិយនេះ ឬក៏នៅបរលោកក្តី"។

"ហើយវេទនាដល់អស់អ្នកណា ដែលពុំចូលមកក្នុងពព្វជិតភាពនេះ ដែលអ្នករាល់គ្នាបានទទួល ដែលយើងកំពុងតែបញ្ជាក់មកលើអ្នកឥឡូវនេះ ដែលជាអ្នកមានវត្តមាននៅថ្ងៃនេះ ដោយសារសម្លេងរបស់យើងផ្ទាល់ចេញមកពីលើមេឃ ហើយគឺយើងនេះហើយ ដែលបានបង្គាប់ដល់ពួកពលបរិវារនៅលើស្ថានសួគ៌ និងពួកទេវតារបស់យើងពីដំណើរអ្នក។ ហើយឥឡូវនេះ យើងប្រទានបញ្ញត្តិមួយដល់អ្នក ដើម្បីឱ្យប្រយ័ត្នប្រយែងខ្លួន ដើម្បីព្យាយាមស្តាប់តាមព្រះបន្ទូលទាំងឡាយអំពីជីវិតដ៏នៅអស់កល្បជានិច្ច"។[1]

ឥឡូវនេះបើអ្នកដូចជាខ្ញុំ នៅពេលដែលខ្ញុំបានឮពាក្យទាំងនោះដំបូង កាលពីនៅក្មេង ការសំណូមពរឱ្យទទួលយកបព្វជិតភាពមិលគីស្សាដែក អាចនឹងហាក់ដូចជាមានការរុញរា។ មានយ៉ាងហោចណាស់នូវមូលហេតុពីរយ៉ាងថាហេតុអ្វីអ្នកគួរតែមានទំនុកចិត្ត ជាជាងបាក់ទឹកចិត្តជាមួយនឹងទណ្ឌកម្ម ដែលនឹងកើតមាននៅពេលដែលមិនគោរពតាមសម្បថ និងសេចក្តីសញ្ញា ហើយមើលឃើញថាវាមានការលំបាកពេក ឬបើអ្នកមិនសាកល្បង នោះទណ្ឌកម្មក៏នៅមានដូចគ្នា។ ហេតុដូច្នេះហើយ មិនបាច់ឆ្ងល់ទេ ផ្លូវដែលល្អបំផុតរបស់អ្នក និងខ្ញុំ គឺត្រូវទទួលបព្វជិតភាពបរិសុទ្ធ ហើយព្យាយាមដោយអស់ពីចិត្តរបស់យើងដើម្បីរក្សាសេចក្តីសញ្ញានោះ។ បើយើងជ្រើសរើសមិនសាកល្បង យើងនឹងច្បាស់ជាបាត់បង់ឱកាសចំពោះជីវិតដ៏នៅអស់កល្បជានិច្ច។ បើយើងសាកល្បង ហើយព្រមជាមួយនឹងជំនួយរបស់ព្រះឱ្យជោគជ័យ នោះយើងនឹងទទួលជីវិតដ៏នៅអស់កល្បជានិច្ច។

មានមូលហេតុមួយទៀតដើម្បីសម្រេចចិត្តនៅពេលនេះថា អ្នកនឹងព្យាយាមដោយអស់ពីចិត្តរបស់អ្នក ដើម្បីបំពេញតាមសម្បថ និងសេចក្តីសញ្ញា ហើយមានទំនុកចិត្តថាអ្នកនឹងទទួលជោគជ័យ។ បើអ្នកអនុវត្តសេចក្តីជំនឿ ព្រះសន្យានឹងអ្នកថា ជំនួយ និងព្រះចេស្តារនឹងប្រទានឱ្យអ្នកដើម្បីអ្នកទទួលបានជោគជ័យ។

ខ្ញុំសូមពិពណ៌នាអំពីពរជ័យមួយចំនួន ដែលអ្នកនឹងទទួលនៅពេលអ្នកបន្តឆ្ពោះទៅមុខដោយក្តីជំនឿ។ *ទីមួយ* ជាកត្តាយ៉ាងច្បាស់ថា អ្នកត្រូវបានផ្តល់ឱ្យនូវសម្បថ និងសេចក្តីសញ្ញា ជាភស្តុតាងថា ព្រះបានជ្រើសរើសអ្នកដោយដឹងអំពីអំណាច និងសមត្ថភាពរបស់អ្នក។ ទ្រង់បានស្គាល់អ្នកតាំងពីអ្នកនៅជាមួយនឹងទ្រង់ នៅក្នុងពិភពនៃវិញ្ញាណមុនជីវិតនេះ។ ដោយសារបុព្វវិជ្ជារបស់ទ្រង់នៃកម្លាំងរបស់អ្នក ទ្រង់បានអនុញ្ញាតឱ្យអ្នករកឃើញសាសនាចក្រពិតរបស់ព្រះយេស៊ូវគ្រីស្ទ និងត្រូវបានប្រគល់ឱ្យនូវបព្វជិតភាព។ អ្នកអាចមានអារម្មណ៍ទំនុកចិត្ត ដោយសារអ្នកមានភស្តុតាងនៃទំនុកចិត្តរបស់ទ្រង់មកលើអ្នក។

*ទីពីរ* នៅពេលអ្នកនឹងព្យាយាមដើម្បីរក្សាតាមសេចក្តីសញ្ញាទាំងឡាយរបស់អ្នក ព្រះអង្គសង្គ្រោះសន្យាថាទ្រង់នឹងជួយដោយផ្ទាល់។ ទ្រង់បានមានប្រសាសន៍ថា នៅពេលអ្នកឆ្ពោះទៅមុខដោយការគោរពដល់បព្វជិតភាព "...នោះយើងក៏នឹងនៅទីនោះដែរ ត្បិតយើងនឹងទៅពីមុខអ្នក។ យើងនឹងនៅខាងស្តាំដៃអ្នក ហើយខាងឆ្វេងដៃអ្នក ហើយព្រះវិញ្ញាណរបស់យើងនឹងសណ្ឋិតនៅក្នុងដួងចិត្តរបស់អ្នក ហើយពួកទេវតារបស់យើងនៅព័ទ្ធជុំវិញអ្នកដើម្បីទ្រអ្នកឡើង"។[2]

ពេលខ្លះអ្នកអាចត្រូវការការអះអាងជាថ្មី ដូចដែលខ្ញុំធ្វើ ដើម្បីអ្នកនឹងមានកម្លាំងបំពេញកាតព្វកិច្ចរបស់អ្នកនៅក្នុងបព្វជិតភាពពិសិដ្ឋនេះ។ ព្រះអម្ចាស់បានទតឃើញជាមុននូវតំរូវការនៃការអះអាងជាថ្មីរបស់អ្នក។ ទ្រង់មានព្រះបន្ទូលថា " ត្បិតអស់អ្នកណាដែលស្មោះត្រង់ក្នុងកាលបានបព្វជិតភាពទាំងពីរនេះ ដែលយើងបានពោលដល់

ហើយបានដំកើងការហៅរបស់ខ្លួន នោះត្រូវបានញែកជាបរិសុទ្ធ ហើយបានដំកើងការហៅរបស់ខ្លួន នោះត្រូវបានញែកជាបរិសុទ្ធដោយសារព្រះវិញ្ញាណ ចំពោះការសាងរូបកាយរបស់ពួកគេជាថ្មី"។[3]

ខ្ញុំបានឃើញការសន្យានេះបានសម្រេចនៅក្នុងជីវិតរបស់ខ្ញុំផ្ទាល់ និងនៅក្នុងជីវិតរស់នៅរបស់អ្នកដទៃ។ មិត្តរបស់ខ្ញុំម្នាក់ បានបំរើជាប្រធានបេសកកម្ម។ គាត់បានប្រាប់ខ្ញុំថា នៅចុងបញ្ចប់នៃថ្ងៃនីមួយៗ ខណៈដែលគាត់បំរើហើយ គាត់អាចមានតែកម្លាំងដើម្បីឡើងទៅជាន់លើដើម្បីគេងប៉ុណ្ណោះ ហើយយប់នោះគាត់ងឿងឆ្ងល់ថា តើគាត់នឹងមានកម្លាំងដើម្បីប្រឈមមុខនៅថ្ងៃថ្មីឬទេ។ បន្ទាប់មក នៅពេលព្រឹកឡើង គាត់នឹងបានកម្លាំង និងភាពក្លាហានឡើងវិញ។ អ្នកបានមើលឃើញនៅក្នុងជីវិតរស់នៅរបស់ព្យាការីពីមុនៗ ដែលហាក់ដូចជាទទួលបានកម្លាំងជាថ្មីរាល់ពេលដែលពួកលោកបានក្រោកឈរដើម្បីធ្វើទីបន្ទាល់ អំពីព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អដែលបានស្តារឡើងវិញ។ នោះគឺជាការសន្យាសំរាប់អ្នកទាំងឡាយណា ដែលបានឆ្ពោះទៅមុខនៅក្នុងសេចក្តីជំនឿនៅក្នុងការបំរើបព្វជិតភាពរបស់ពួកគេ។

អ្នកក៏ត្រូវបានសន្យាផងដែរថា អ្នកនឹងត្រូវបានប្រទានឱ្យនូវអំណាចដើម្បីថ្លែងទីបន្ទាល់ ហើយថានៅក្នុងដំណើរការអ្នកនឹងត្រូវបានសំអាត ហើយធ្វើឱ្យសក្តិសមសំរាប់ជីវិតដ៏នៅអស់កល្បជានិច្ច ដែលអ្នកត្រូវបានសន្យាថា ៖

"ត្បិតយើងនឹងអត់ទោសអំពើបាបទាំងឡាយដល់អ្នក ព្រមទាំងព្រះបញ្ញត្តិនេះផងដែរ--- ប្រយោជន៍ឱ្យអ្នកនៅខ្ជាប់ខ្ជួនក្នុងគំនិតអ្នក ក្នុងភាពម៉ឺងម៉ាត់ នឹងវិញ្ញាណខាងការអធិស្ឋាន ក្នុងការថ្លែងទីបន្ទាល់ដល់សព្វក្នុងលោកិយទាំងមូល អំពីការណ៍ទាំងនោះដែលបានប្រាប់ដល់អ្នក។

"ហេតុដូច្នោះហើយ ចូរអ្នករាល់គ្នាទៅសព្វក្នុងលោកិយទាំងមូល និងដល់កន្លែងណាក៏ដោយ ដែលអ្នករាល់គ្នាពុំអាចទៅបាន នោះអ្នករាល់គ្នាត្រូវធ្វើ ប្រយោជន៍ឱ្យទីបន្ទាល់នោះអាចបានចេញពីអ្នក ទៅសព្វក្នុងលោកិយទាំងមូលដល់គ្រប់មនុស្សទាំងអស់"។[4]

ហើយជាមួយនឹងការសន្យានោះ ព្រះអម្ចាស់បានគោរពអ្នក ដោយមានបន្ទូលអំពីអ្នកថា "អ្នករាល់គ្នានេះហើយជាពួកអ្នកដែលព្រះវរបិតារបស់យើងបានប្រទានដល់យើង អ្នករាល់គ្នាជាមិត្តរបស់យើង"។

មានពរជ័យដ៏អស្ចារ្យផ្សេងទៀត ដែលនឹងលើកទឹកចិត្តអ្នក នៅពេលអ្នករក្សាសេចក្តីសញ្ញាបព្វជិតភាពរបស់អ្នក។ ការបំរើបព្វជិតភាពនឹងរៀបចំអ្នកឱ្យរស់នៅក្នុងក្រុមគ្រួសារដ៏នៅអស់កល្បជានិច្ច។ វានឹងផ្លាស់ប្តូរអារម្មណ៍របស់អ្នកអំពីអត្ថន័យនៃការធ្វើជាស្វាមី ជាឪពុក ជាកូនប្រុស ឬជាបងប្អូនប្រុស។ ការផ្លាស់ប្តូរនៅក្នុងដួងចិត្តរបស់អ្នកនោះនឹងកើតមាន នៅពេលអ្នកទទួលអារម្មណ៍ថាសេចក្តីជំនឿរបស់អ្នករីកចំរើន ហើយការសន្យាអំពីជីវិតដ៏នៅអស់កល្បជានិច្ចតាមរយៈបព្វជិតភាពមិលគីស្សាដែកក្លាយជាការពិតចំពោះអ្នក។

រឿងនោះបានកើតឡើងចំពោះ ប៉ាលី ភី ប្រាត្ត នៅពេលព្យាការីយ៉ូសែប ស៊្មីធ បង្រៀនដល់គាត់ដំបូងអំពីគោលលទ្ធិនៃក្រុមគ្រួសារដ៏នៅអស់កល្បជានិច្ច។ ប៉ាលី ភី ប្រាត្ត បានសរសេរថា ៖ "នេះគឺជាលើកទីមួយ ដែលខ្ញុំបានទទួលមកពីលោកនូវគំនិតដំបូង អំពីអង្គការគ្រួសារដ៏នៅអស់កល្បជានិច្ច និងការរួបរួមគ្នាដ៏នៅអស់កល្បជានិច្ចនៃមនុស្សទាំងពីរភេទ ដែលមិនអាចពិពណ៌នាបាន ស៊្វូទ្រាំនៅក្នុងទំនាក់ទំនង ដែលគ្មានអ្វីផ្សេង ក្រៅពីបេះដូងដែលប្រកបដោយ

បញ្ញាដ៏ខ្ពង់ខ្ពស់ ធ្វើឱ្យស្អាតស្អំ និងបរិសុទ្ធ ដឹងរបៀបដើម្បីឱ្យតម្លៃ និងជាគ្រឹះនៅគ្រប់អ្វីដែលសក្តិសម ដែលត្រូវបានហៅថា សុភមង្គល...។

នោះជាអ្វីដែលខ្ញុំបានរៀនមកពីលោក ដែលថាភរិយានៅក្នុងដើមទ្រូងរបស់ខ្ញុំអាចនឹងជាសុវត្ថិភាពចំពោះខ្ញុំ សំរាប់ពេលនេះ និងនៅអស់កល្បជានិច្ច ហើយថា ការស្អាងឡើងនូវក្តីអាណិតអាសូរ និងក្តីស្រឡាញ់ ដែលធ្វើឱ្យយើងស្រឡាញ់គ្នាទៅវិញទៅមក បានភាយចេញនូវប្រភពនៃសេចក្តីស្រឡាញ់ដ៏នៅអស់កល្បជានិច្ចដ៏ទេវភាព។ គឺមកពីលោក ដែលខ្ញុំបានរៀនថា យើងអាចបណ្តុះសេចក្តីស្រឡាញ់ទាំងនេះ ហើយរីកចំរើន និងបង្កើតក្តីស្រឡាញ់ដូចគ្នាសំរាប់ភាពអស់កល្បជានិច្ច ខណៈដែលលទ្ធផលនៃការរួបរួមគ្នាដ៏គ្មានទីបញ្ចប់របស់យើង នឹងមានជាកូនចៅយ៉ាងច្រើនឥតគណនា ដូចជាផ្កាយនៅលើស្ថានសួគ៌ ឬខ្សាច់នៅលើឆ្នេរសមុទ្រ...។

ខ្ញុំមានក្តីស្រឡាញ់ពីមុនមក ប៉ុន្តែខ្ញុំមិនដឹងថាមូលហេតុអ្វីទេ។ ប៉ុន្តែឥឡូវនេះខ្ញុំស្រឡាញ់--- ដោយភាពបរិសុទ្ធ---ដោយប្រពលភាពនៃអារម្មណ៍លើកដំកើង...។ ខ្ញុំទទួលអារម្មណ៍ថា ព្រះគឺជាព្រះវរបិតាសួគ៌របស់ខ្ញុំដ៏ពិតថាព្រះយេស៊ូវ គឺជាបងប្រុសរបស់ខ្ញុំ ហើយថាភរិយានៅក្នុងដើមទ្រូងរបស់ខ្ញុំ គឺជាដៃគូរអមត និងដ៏នៅអស់កល្បជានិច្ចជាទេវតាចិត្តល្អ និងទេវតានៃការបំរើដែលប្រទានមកឱ្យខ្ញុំ ធ្វើជាអ្នកលួងលោម និងជាមកុដនៃសិរីល្អមួយ ដែលប្រទានមកខ្ញុំជារៀងរហូតតទៅ"។[6]

ខ្ញុំគឺជាសាក្សីផ្ទាល់ថា ការបំរើបព្វជិតភាពអនុវត្តនៅក្នុងសេចក្តីជំនឿ មានឥទ្ធិពលនៅក្នុងការផ្លាស់ប្តូរដួងចិត្តរបស់យើង និងអារម្មណ៍របស់យើង។ ហើយយុវជនដែលបានស្តាប់ពាក្យរបស់ខ្ញុំនៅថ្ងៃនេះ អាចមានទំនុកចិត្តថា ដោយការគោរពបព្វជិតភាពរបស់គាត់ នោះគាត់នឹងត្រូវបានការពារពីការល្បួងឱ្យមានអំពើបាបខាងកាមគុណ ដែលមានជាទូទៅនៅក្នុងពិភពលោក ដែលយើងរស់នៅនេះ។ វានឹងអាចឱ្យអ្នកកាន់បព្វជិតភាពអើរ៉ុន ស្តាប់ឮខ្ញុំនៅយប់នេះថា នៅពេលសេចក្តីជំនឿរបស់គាត់កើនឡើង នៅក្នុងភាពពិតប្រាកដ ចំពោះរង្វាន់នៃជីវិតដ៏នៅអស់កល្បជានិច្ច តាមរយៈបព្វជិតភាពដ៏អស់កល្បជានិច្ច នោះគាត់នឹងមានអំណាចដើម្បីមើលឃើញតម្លៃពិតប្រាកដរបស់បុត្រីទាំងឡាយរបស់ព្រះ និងមើលឃើញនៅក្នុងការសន្យានៃភាពចំរុងចំរើន ដោយមូលហេតុបរិសុទ្ធ និងនៅស្អាតស្អំ។

នៅក្នុងរបៀបដូចគ្នា សេចក្តីជំនឿនៅក្នុងសម្បថ និងសេចក្តីសញ្ញានឹងដឹកនាំអ្នកឱ្យអភិវឌ្ឍអារម្មណ៍នៃសប្បុរសធម៌ដែលសំខាន់ចំពោះគ្រួសារដ៏នៅអស់កល្បជានិច្ច។ ការសន្យាមួយនៃការសន្យាទាំងនោះ ដែលយើងធ្វើនៅពេលយើងទទួលបព្វជិតភាព គឺដើម្បីយកចិត្តទុកដាក់ទៅលើអ្នកដទៃ។

ខ្ញុំបានឃើញអព្ភូតហេតុនៃការរីកចំរើនខាងសប្បុរសធម៌នោះ នៅក្នុងដួងចិត្តរបស់អ្នកកាន់បព្វជិតភាព។ ក៏ដូចជាអ្នករាល់គ្នាជាច្រើនផងដែរ។ ហើយនឹងមនុស្សជាច្រើននៅក្រៅសាសនាចក្រ។ ខ្ញុំនៅក្នុងការិយាល័យរបស់ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី នៅពេលលោកបានសុំឱ្យខ្ញុំទទួលទូរស័ព្ទ។ លោកបានមានប្រសាសន៍យ៉ាងខ្លីតាមទូរស័ព្ទ ហើយត្រឡប់មកការសន្ទនារបស់យើងវិញ។ ប៉ុន្តែលោកបានចំណាយពេលមួយសន្ទុះពន្យល់។ លោកមានប្រសាសន៍ថា ទូរស័ព្ទនោះគឺមកពីប្រធានាធិបតីសហរដ្ឋ ដែលនឹងធ្វើដំណើរមករដ្ឋយូថាហ៍តាមកងទ័ពអាកាស ពេលធ្វើដំណើរទៅវ៉ាស៊ីនតោន។ ប្រធានាធិបតីសហរដ្ឋបានទូរស័ព្ទមកអរគុណប្រធាន ហ៊ិងគ្លី ចំពោះអ្វីដែលអ្នកកាន់បព្វជិតភាពបានធ្វើនៅក្នុងពេលបន្ទាប់ពីខ្យល់ព្យុះ។ ប្រធានាធិបតីសហរដ្ឋ បានមានប្រសាសន៍ថា វាគឺជាអព្ភូតហេតុមួយដែលយើងអាច

ប្រមូលមនុស្សយ៉ាងច្រើនបានឆាប់រហ័ស ហើយធ្វើការជាមួយគ្នាបានយ៉ាងល្អ។ លោកបានសរសើរប្រជាជនយើង ដោយមានប្រសាសន៍ថា យើងចេះធ្វើការងារដោយជោគជ័យ។

ប្រហែលជាប្រធានាធិបតីសហរដ្ឋ មានចំណាប់អារម្មណ៍នឹងអ្វីដែលលោកបានគិតថានោះគឺជា ជំនាញខាងការរៀបចំដ៏អស្ចារ្យទាំងឡាយរបស់យើង។ នោះគឺជាចំណែកនៃអព្ភូតហេតុ។ ប៉ុន្តែមូលហេតុដែលអស្ចារ្យជាងនោះ ចំពោះអព្ភូតហេតុ គឺអ្នកកាន់បព្វជិតភាពរាប់រយ ប្រហែលជារាប់ពាន់អ្នក មានសេចក្តីជំនឿនៅក្នុងសម្បថ និងសេចក្តីសញ្ញាបព្វជិតភាព។ មិនមែនដោយសាររបៀប ដែលពួកគេត្រូវបានរៀបចំឡើង ធ្វើឱ្យមានភាពខុសគ្នានោះទេ សេចក្តីជំនឿនៅក្នុងសម្បថ និងសេចក្តីសញ្ញានៃបព្វជិតភាពជំរុញឱ្យពួកគេធ្វើដំណើរទៅចម្ងាយផ្លូវឆ្ងាយៗ នៅរាប់ម៉ោង ហើយស៊ូទ្រាំនឹងការលំបាក ក្នុងនាមជាអ្នកតំណាងឱ្យព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ នៅក្នុងការយកចិត្តទុកដាក់ចំពោះអ្នកទាំងឡាយដែលមានតំរូវការយ៉ាងខ្លាំង។

ពួកគេនៅក្នុងដំណើរការនោះ ដើម្បីផ្តល់ការបំរើបព្វជិតភាព និងអភិវឌ្ឍកម្លាំង និងវិញ្ញាណនៃសប្បុរសធម៌ ដែលចាំបាច់ដើម្បីក្លាយជាស្វាមី ឪពុក កូនប្រុស និងបងប្អូនប្រុសដ៏ល្អនៅក្នុងក្រុមគ្រួសារនៅទីនេះ និងនៅក្នុងក្រុមគ្រួសារដ៏នៅអស់កល្បជានិច្ច។ ឧទាហរណ៍នៃការបំរើបព្វជិតភាពទាំងនោះ បានកើតមានឡើងនៅក្នុងការឈោងទៅរកប្រជាជនរបស់យើង ក្នុងនាមជាបងប្អូនប្រុសស្រីនៅក្នុងគ្រួសាររបស់ព្រះនៅទូទាំងផែនដី ម្តងហើយម្តងទៀត។

ការអធិស្ឋានរបស់ខ្ញុំគឺថាអ្នកនឹងសម្រេចចិត្តនៅយប់នេះ រួចហើយរៀងរាល់ថ្ងៃ នឹងចេញទៅឆ្ពោះទៅមុខ នៅក្នុងការរក្សាសេចក្តីសញ្ញារបស់អ្នកជាមួយនឹងព្រះ ហើយក៏ទាមទារសេចក្តីសន្យាដែលទ្រង់បានធ្វើនឹងអ្នកជាមួយនឹងសម្បថ។ អ្នកអាចធ្វើវានៅក្នុងរឿងសាមញ្ញៗ។ នៅពេលអ្នកជួបជាមួយនឹងក្រុមរបស់អ្នក អ្នកអាចសម្រេចចិត្តដើម្បីមើលទៅពួកគេ ក្នុងនាមជាបងប្អូនប្រុសនៅក្នុងគ្រួសាររបស់ព្រះ។ នោះនឹងមានមនុស្សម្នាក់នៅក្នុងក្រុម ឬថ្នាក់បព្វជិតភាពដែលមានតំរូវការ។ ទ្រង់ប្រហែលជាមិនបង្ហាញកិច្ចការនោះទេ។ អ្នកប្រហែលជាមិនអាចឃើញវា ដោយភ្នែករបស់អ្នកបានឡើយ ។ប៉ុន្តែព្រះដឹង ហើយអញ្ជើញអ្នកឱ្យធ្វើជាអ្នកបំរើរបស់ទ្រង់ នៅក្នុងការជួយដល់ទ្រង់។

អ្នកក៏អាចដូចជាអ្នកកាន់បព្វជិតភាព ដែលរាល់ពេលខ្ញុំបានឃើញគាត់នៅក្នុងការបំរើបព្វជិតភាពជាមួយគ្នារបស់យើង បានសួរថា "តើលោកយាយសុខទុក្ខយ៉ាងណាដែរ?" គាត់មិនដែលជួបនឹងម្តាយក្មេករបស់ខ្ញុំទេ តាមដែលខ្ញុំដឹង។ ប៉ុន្តែមិនដឹងយ៉ាងម៉េច គាត់បានដឹងអំពីជំងឺរបស់គាត់ ហើយភាពចាស់ជរារបស់គាត់។ ខ្ញុំមិនអាចប្រាប់អ្នកអស់ថាពាក្យនោះមានអត្ថន័យចំពោះខ្ញុំប៉ុណ្ណាទេ ដែលបានមើលឃើញព្រះហស្តរបស់ព្រះបានឈោងមករកខ្ញុំ និងភរិយារបស់ខ្ញុំនៅក្នុងការលួងលោម និងកំសាន្តចិត្តតាមរយៈអ្នកកាន់បព្វជិតភាពម្នាក់។ អ្នកអាចមានឥទ្ធិពលដូចគ្នានេះរាល់ពេលដែលអ្នកជួបជុំជាមួយនឹងអ្នកកាន់បព្វជិតភាព បើអ្នកតែងតែគិតអំពីសេចក្តីសញ្ញារបស់អ្នក ដើម្បីជួយដល់អ្នកទន់ខ្សោយលើកដៃដែលរោយ ហើយដែលមានបន្ទុកយ៉ាងធ្ងន់។ នៅពេលអ្នកធ្វើដូច្នេះ អ្នកនឹងអភិវឌ្ឍគុណសម្បត្តិទាំងអស់ដែលនឹងឱ្យអ្នកមានគុណសម្បត្តិធ្វើជាសមាជិកម្នាក់នៃគ្រួសារដ៏អស់កល្បជានិច្ចមួយ។

មានរឿងមួយទៀត ដែលអ្នកអាចធ្វើ។ អ្នកអាចសិក្សាបន្ទូលរបស់ព្រះ មិនមែនសំរាប់តែខ្លួនអ្នក ប៉ុន្តែជាតំណាងឱ្យព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ចំពោះមនុស្សទាំងអស់ក្នុងពិភពលោក។ នៅពេលអ្នកចំរើនអំណាចរបស់អ្នកដើម្បីបង្រៀនដំណឹងល្អ អ្នកកំពុងតែមានសមត្ថភាពដើម្បីជួយដល់ព្រះវរបិតាសួគ៌ នៅក្នុងការប្រមូលកូនចៅរបស់ទ្រង់។

នៅពេលអ្នកធ្វើដូច្នោះ ពរជ័យមួយទៀតនឹងប្រទានឱ្យ។ តើមានសេចក្តីត្រូវការនៅក្នុងជីវិតគ្រួសារក្នុងពិភពលោកនេះ ឬនៅក្នុងពិភពលោកបន្ទាប់ ដើម្បីនាំចៀមដែលបាត់បង់ឱ្យមកក្រោលវិញឬទេ បើមាននោះអ្នកនឹងបានទទួលអំណាចកាន់តែខ្លាំងហួសពីអ្នកអាចដឹង ក្នុងពេលឥឡូវនេះ។

ព្រះអម្ចាស់បានពិពណ៌នាពរជ័យដ៏អស្ចារ្យនោះនៅក្នុងអាលម៉ា 13:6: "ហើយដោយហេតុនេះ ត្រូវបានហៅដោយតំណែងដ៏បរិសុទ្ធ ហើយបានតែងតាំងឡើង ក្នុងបព្វជិតភាពជាន់ខ្ពស់នៃរបៀបដ៏បរិសុទ្ធនៃព្រះ ដើម្បីទៅបង្រៀនព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ដល់កូនចៅមនុស្ស ក៏ដើម្បីឱ្យពួកគេអាចចូលទៅក្នុងសេចក្តីសំរាករបស់ទ្រង់ផង"។

អ្នកអាចបានទំនុកចិត្តនៅក្នុងការបំរើរបស់អ្នក ជាមួយនឹងការសន្យានៃភាពជោគជ័យនេះថា:

"ឥឡូវនេះ បន្ទាប់ពីគេត្រូវបានញែកជាបរិសុទ្ធដោយព្រះវិញ្ញាណបរិសុទ្ធ ដោយមានសំលៀកបំពាក់បានធ្វើឱ្យសដោយបានបរិសុទ្ធ ហើយគ្មានទោសនៅចំពោះព្រះ នោះគេពុំអាចសម្លឹងមើលអំពើបាបទៀតឡើយ លើកលែងតែមើលដោយស្អប់ខ្ពើមប៉ុណ្ណោះ ហើយមានមនុស្សជាច្រើនឥតគណនា ដែលបានធ្វើឱ្យបរិសុទ្ធ ហើយចូលទៅក្នុងសេចក្តីសំរាកនៃព្រះអម្ចាស់ជាព្រះរបស់ពួកគេ។ ហើយឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ ខ្ញុំចង់ឱ្យអ្នកបន្ទាបខ្លួនចំពោះព្រះ ហើយនាំមកនូវផលដែល សមនឹងសេចក្តីប្រែចិត្ត ដើម្បីឱ្យអ្នកអាចចូលទៅក្នុងសេចក្តីសំរាកនោះដែរ"។[7]

ខ្ញុំធ្វើទីបន្ទាល់ថាព្រះ ជាព្រះវរបិតាមានព្រះជន្មរស់។ អ្នកបានធ្វើសេចក្តីសញ្ញាជាមួយនឹងទ្រង់។ ទ្រង់បានប្រទានដល់អ្នកនូវសម្បថមួយ ការសន្យាមួយនៃជីវិតដ៏នៅអស់កល្បជានិច្ច ដែលទ្រង់មិនអាចបណ្តាច់បាន។ ខ្ញុំថ្លែងទីបន្ទាល់ដល់អ្នកថា បព្វជិតភាពគឺជាព្រះចេស្តា ដែលព្រះ តាមរយៈព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ បានបង្កើតពិភពលោក។ ខ្ញុំថ្លែងទីបន្ទាល់ថា ព្រះសព្វព្រះទ័យឱ្យអ្នកទទួលជោគជ័យ ហើយត្រឡប់មកផ្ទះរស់នៅជាមួយនឹងទ្រង់ម្តងទៀតនៅក្នុងក្រុមគ្រួសារដ៏នៅអស់កល្បជានិច្ច។ ខ្ញុំថ្លែងទីបន្ទាល់ដល់អ្នកថានេះ គឺជាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទពិត។ នៅក្នុងសាសនាចក្រនេះមាននូវកូនសោបព្វជិតភាព។ ដោយសារបព្វជិតភាពនោះ ដែលព្រះបានគោរពដល់អ្នក។ ខ្ញុំសូមសន្យានឹងអ្នកថា ទ្រង់ស្គាល់សមត្ថភាពរបស់អ្នក ហើយថាសមត្ថភាពនោះមានគ្រប់គ្រាន់ ដើម្បីអ្នកអាចមានក្តីសង្ឃឹមតាមរយៈសេចក្តីជំនឿដ៏ពេញលេញ អំពីជីវិតដ៏នៅអស់កល្បជានិច្ចចំពោះអ្នក និងចំពោះក្រុមគ្រួសាររបស់អ្នកជារៀងរហូត។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. គ. និង ស. 84:35--43។

2. គ. និង ស. 84:88។

3. គ. និង ស. 84:33។

4. គ. និង ស. 84:61--62។

5. គ. និង ស. 84:63។

6. *Autobiography of Parley P. Pratt*, ed. Parley P. Pratt Jr.(1938) ទំព័រ 259--260។

7. អាលម៉ា 13:6។